# ព្រះរាជក្រឹត្យ

**នស/រកត/០៨០៧/៣៧៣ ស្តីពី**

## ការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យ វេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រម លេខជស/រកម/១១៧៩/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈគិលានុបដ្ឋាកមួយ ដើម្បីប្រមូលផ្តុំគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ទាំងអស់ ដែលមាននីតិសម្បទាគ្រប់គ្រាន់ អាចប្រកបវិជ្ជាជីវៈ ជំនួយវេជ្ជសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ពាក្យថា គិលានុបដ្ឋាកក្នុងព្រះរាជក្រឹត្យនេះ ប្រើសំដៅយកនីតិជន ដែលមានសញ្ញាប័ត្រគិលានុបដ្ឋាក ចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬសញ្ញាប័ត្រគិលានុបដ្ឋាក ចេញដោយគ្រឹះស្ថានសិក្សា ដែលបានទទួលស្គាល់គុណភាពអប់រំដោយ គណៈកម្មាធិការទទួល ស្គាល់គុណភាពអប់រំនៃកម្ពុជា ។

គិលានុបដ្ឋាក គិលានុបដ្ឋាយិកា ទាំងអស់ ដែលប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រ ត្រូវសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈគិលានុបដ្ឋាក ។

## ជំពូកទី ២

## បេសកកម្មរបស់គណៈគិលានុបដ្ឋាក

**មាត្រា ៣.-**

គណៈគិលានុបដ្ឋាក ត្រូវឃ្លាំមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍សីលធម៌ ភាពសុចរិតយុត្តិធម៌ និង ភក្តីភាពចាំបាច់ ក្នុងការប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈគិលានុបដ្ឋាក ត្រូវឃ្លាំមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈព្រមទាំងបទប្បញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងក្រមសីលធម៌គិលានុបដ្ឋាក ។

គណៈគិលានុបដ្ឋាក ធានាការពារកិត្តិយស និង ឥស្សរភាពរបស់វិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រ ។

គណៈគិលានុបដ្ឋាកបំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈគិលានុបដ្ឋាក ខេត្ត ក្រុង ដែលសរសេរអក្សរកាត់ថា ក.គិ.ខ. ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគ ដែលសរសេរអក្សរកាត់ថា ក.គិ.ភ. និងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ដែលសរសេរអក្សរកាត់ថា ក.គិ.ជ. ។

## ផ្នែកទី ១
## តួនាទីសីលធម៌

### មាត្រា ៤.-

គណៈគិលានុបដ្ឋាក មានបន្ទុករៀបចំ ក្រមសីលធម៌គិលានុបដ្ឋាក យកលំនាំតាមលក្ខណៈចាំបាច់ នៃវិជ្ជាជីវៈ ក្នុងការវិវត្តខ្ជាប់ខ្ជួនខាងបច្ចេកទេសសេដ្ឋកិច្ច និងសង្គមកិច្ច ដែលត្រូវធ្វើឱ្យវិវត្តល្អក្នុងផលប្រយោជន៍របស់អ្នកជំងឺ ។

គណៈគិលានុបដ្ឋាកតាមឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ និងសេចក្តីគោរពប្រណិបត្តិ ។

គណៈគិលានុបដ្ឋាក ជាអង្គការស្វយ័តក្នុង ការចំណាយ ការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ដើម្បីធានាឥស្សរភាពការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

## ផ្នែកទី ២
## តួនាទីគ្រប់គ្រងរដ្ឋបាល

### មាត្រា ៥.-

ការចាត់ចែងអំណាចត្រូវអនុលោមតាមបញ្ជាគណៈគិលានុបដ្ឋាក ។

គណៈគិលានុបដ្ឋាកត្រូវរៀបចំធ្វើ និងថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលបានចុះឈ្មោះបំពេញល័ក្ខខ័ណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ចនៃការចុះឈ្មោះ ក្នុងបញ្ជីរាយនាមគិលានុបដ្ឋាក គិលានុបដ្ឋាកយិកា គឺដើម្បីបំពេញការរៀបចំថែទាំអ្នកជំងឺ ។

គណៈគិលានុបដ្ឋាកជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលល័ក្ខខ័ណ្ឌនៃការប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រនេះ ។

## ផ្នែកទី ៣
## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

### មាត្រា ៦.-

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់គិលានុបដ្ឋាក គិលានុបដ្ឋាយិកាណាមួយទៅ គណៈគិលានុបដ្ឋាក មិនមែនជាឧបសគ្គក្នុងការធ្វើបណ្តឹង ចំពោះការប្រព្រឹត្តខុសឆ្គងនេះ ទៅតុលាការឡើយ ។

## ផ្នែកទី ៤

## តួនាទីពិភាក្សាផ្តល់យោបល់

### មាត្រា ៧.-

គណៈគិលានុបដ្ឋាក អាចត្រូវបានកោះហៅឱ្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រទាំងឡាយ ។

## ផ្នែកទី ៥

## តួនាទីជួយសង្គ្រោះគ្នាទៅវិញទៅមក

### មាត្រា ៨.-

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះ មានបច្ច័យដល់គិលានុបដ្ឋាក គិលានុបដ្ឋាយិកា និងគ្រួសាររបស់គេ។ ការជួយសង្គ្រោះគ្នាបានរៀបចំតាមបែបបទដូចតទៅ ÷

- គណៈគិលានុបដ្ឋាកត្រូវមានក្នុងថវិការបស់ខ្លួន ប្រាក់បម្រុងសម្រាប់ជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីឱ្យប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាមៗ ក្នុងករណីសមរម្យដល់គ្រួសារគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលរងទុកលំបាក
- គណៈគិលានុបដ្ឋាកត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមគិលានុបដ្ឋាកកម្ពុជាម្នាក់ ជាសមាជិក
- គណៈកម្មការនេះ ចាត់ចែងឱ្យមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់វិភាគទានពីគិលានុបដ្ឋាក គិលានុបដ្ឋាយិកាម្នាក់ៗដែលចុះឈ្មោះ ក្នុងគណៈគិលានុបដ្ឋាក ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

## ផ្នែកទី ១

## ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកថ្នាក់ខេត្ត ក្រុង (ក.គិ.ខ.)

### មាត្រា ៩.-

ក.គិ.ខ. ត្រូវបង្កើតនៅតាមខេត្ត ក្រុងនិមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំពោះខេត្ត ក្រុង ដែលមានចំនួនគិលានុបដ្ឋាក គិលានុបដ្ឋាយិកាតិចជាងម្ភៃ (២០) នាក់ ត្រូវបញ្ចូលទៅខេត្តដែលនៅជិតជាងគេ ដើម្បីបង្កើតក្រុមប្រឹក្សាគណៈគិលានុបដ្ឋាក ។

## មាត្រា ១០.-

ក.គិ.ខ.ត្រូវមានសមាជិកពេញសិទ្ធិចំនួនប្រាំបួន០៩ ( ប្រាំបួន)រូប និងសមាជិកជំនួសចំនួន០៩ ( ប្រាំបួន )រូប ក្នុងករណីដែលចំនួនគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលបានចុះឈ្មោះក្នុងបញ្ជីមានមិនលើសពី១០០( មួយរយ) នាក់។ ចំនួននេះនឹងឡើងទៅដល់១១ ( ដប់មួយ) ១៥ ( ដប់ប្រាំ) ១៩ ( ដប់ប្រាំបួន) ឬ ២១ ( ម្ភៃមួយ) រូប បើសិនចំនួនគិលានុបដ្ឋាក គិលានុបដ្ឋាយិកានៅក្នុងបញ្ជីមានលើសពី ១០០ ( មួយរយ) ៥០០ ( ប្រាំរយ) ១០០០ ( មួយពាន់) ឬ ២០០០ ( ពីរពាន់) នាក់ ។

## មាត្រា ១១.-

ក.គិ.ខ. ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយបណ្តាគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលបានចុះឈ្មោះនៅក្នុងបញ្ជីរបស់ ក.គិ.ខ. សំរាប់រយៈពេល០៦ ( ប្រាំមួយ) ឆ្នាំ ។

សមាជិកចប់អាណត្តិ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសសារជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេល០២ ( ពីរ) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ ( មួយភាគបី) នៃសមាជិករបស់ក្រុមប្រឹក្សា។ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ក្នុងករណីដែលចំនួនសមាជិកផ្លាស់ប្តូរ មានចំនួនចែកមិនដាច់។

ការិយាល័យរបស់ ក.គិ.ខ. រួមមាន ប្រធានក្រុមប្រឹក្សា ០១ ( មួយ) រូប អនុប្រធាន ០១ ( មួយ) រូប អគ្គលេខាធិការ០១ ( មួយ) រូប ហេរញ្ញិក០១ ( មួយ) រូប និងសមាជិក០៥ ( ប្រាំ) រូប ។

## មាត្រា ១២.-

ក.គិ.ខ. បំពេញការងារនៅក្នុងក្របខ័ណ្ឌខេត្ត -ក្រុងរបស់ខ្លួន និង ក្រោមការត្រួតពិនិត្យរបស់គណៈគិលានុបដ្ឋាកជាតិចំពោះសមត្ថកិច្ចទូទៅទាំងឡាយ ដែលមានចែងក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ។ ក.គិ.ខ. សំរេចអារកាត់ក្នុងការចុះឈ្មោះគិលានុបដ្ឋាក-គិលានុបដ្ឋាយិកាដែលបានបំពេញល័ក្ខខ័ណ្ឌតាមមាត្រា៣ ជំពូកទី១ មាត្រា៦ ជំពូកទី២នៃច្បាប់ ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ នៅក្នុងបញ្ជីរបស់គណៈគិលានុបដ្ឋាក។ ក.គិ.ខ. មិនប្រកាន់ភេទ ជំនឿសាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតរបស់សមាជិកខ្លួនឡើយ ។

## មាត្រា ១៣.-

ក.គិ.ខ. ពុំមានអំណាចដាក់វិន័យទេ។ បើមានពាក្យបណ្តឹងចំពោះគិលានុបដ្ឋាក ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ក.គិ.ខ. ត្រូវបញ្ជូនបណ្តឹងនោះទៅក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគ ដោយបញ្ជាក់

ហេតុផលច្បាស់លាស់ ។

## មាត្រា ១៤.-

ប្រធានតំណាងឱ្យ ក.គិ.ខ. នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

## មាត្រា ១៥.-

ការប្រជុំនៃក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកខេត្ត ក្រុង នឹងមិនធ្វើជាសាធារណៈឡើយ។ កាលណាមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាពសំរេច។ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ត្រូវបានអញ្ជើញចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គ្រាន់តែមានសម្លេងពិគ្រោះយោបល់។ ក.គិ.ខ. អាចអញ្ជើញទីប្រឹក្សាច្បាប់ មួយរូបចូលរួមក្នុងអង្គប្រជុំ។

## មាត្រា ១៦.-

គិលានុបដ្ឋាក គិលានុបដ្ឋាយិកា នៅតាមបណ្តាខេត្ត ក្រុង ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជីដែលកាន់កាប់ជាប្រចាំដោយក្រុមប្រឹក្សាគណៈ គិលានុបដ្ឋាកខេត្ត ក្រុងពាក់ព័ន្ធ។ អាចចុះឈ្មោះនៅក្នុងបញ្ជីគណៈគិលានុបដ្ឋាកតែចំពោះគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលមានសញ្ញាប័ត្រគិលានុបដ្ឋាក ចេញដោយក្រសួងសុខាភិបាល ឬសញ្ញាប័ត្រចេញដោយគ្រឹះស្ថានសិក្សាដែល ទទួល ស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រ និង បានបំពេញល័ក្ខខ័ណ្ឌច្បាប់ និងក្រមសីលធម៌ដែលបានកំណត់។

គិលានុបដ្ឋាក គិលានុបដ្ឋាយិកា អាចចុះឈ្មោះបានតែនៅក្នុងបញ្ជីនៃ ខេត្ត ក្រុងដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

## មាត្រា ១៧.-

ក.គិ.ខ.ត្រូវសំរេចលើការសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរ០៣(បី)ខែ ដោយគិតចាប់តាំងពីថ្ងៃទទួលពាក្យ ដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេលមួយសប្តាហ៏យ៉ាងយូរក្រោយការសំរេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសិដ្ឋទៅគិលានុបដ្ឋាក គិលានុបដ្ឋាកយិកាសាមី ។ បើមានការបដិសេធលើសំណើរសុំចុះឈ្មោះ ក.គិ.ខ.ត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ជា លាយលក្ខណ៏អក្សរ។

ការអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈគិលានុបដ្ឋាកខេត្ត ក្រុងនិមួយៗត្រូវជូនដំណឹងយ៉ាងយូរពីរសប្តាហ៏ ទៅអាជ្ញាធរខេត្ត ក្រុង ទៅព្រះរាជអាជ្ញានៃខេត្ត ក្រុងពាក់ព័ន្ធ និងទៅក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ។

**មាត្រា ១៨.-**

ក្រោយពីបានអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជី គណៈគិលានុបដ្ឋាកខេត្ត ក្រុង ដែលខ្លួនកំពុងប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក គិលានុបដ្ឋាក-យិកាអាចប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្រ្តនៅខេត្ត ក្រុង ដែលខ្លួនបានចុះឈ្មោះប៉ុណ្ណោះ ។ ក្នុងករណីមានការផ្លាស់ប្តូរលំនៅស្ថានវិជ្ជាជីវៈទៅក្រៅខេត្ត ក្រុង ដែលខ្លួនបានសុំចុះឈ្មោះ គិលានុបដ្ឋាក គិលានុបដ្ឋាយិកា ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់និងត្រូវធ្វើពាក្យសុំចុះឈ្មោះសារជាថ្មីទៅក្រុមប្រឹក្សាខេត្ត ក្រុង ដែលខ្លួនទៅរស់នៅប្រកបវិជ្ជាជីវៈ ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកខេត្ត -ក្រុង ត្រូវទទួលបណ្តឹងជំទាស់ពីក្រុមប្រឹក្សាជាតិ សមាគមគិលានុបដ្ឋាករដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត -ក្រុង ព្រះរាជអាជ្ញាអមតុលាការ ឬ គិលានុបដ្ឋាក គិលានុបដ្ឋាយិកាណាម្នាក់ ដែលបានចុះឈ្មោះនៅក្នុង បញ្ជីគណៈគិលានុបដ្ឋាក រួចហើយធ្វើរបាយការណ៍ផ្ញើជូនគណៈគិលានុបដ្ឋាកជាតិ ។

## ផ្នែកទី ២

## ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគ (ក.គិ.ភ.)

**មាត្រា ២០.-**

ការបែងចែកភូមិភាគសំរាប់គណៈគិលានុបដ្ឋាកកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ÷

ភូមិភាគ១ : រួមមានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ ។

ភូមិភាគ២ : មានខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង ។

ភូមិភាគ៣ : មានខេត្តតាកែវ កំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប មានទីតាំងនៅខេត្តកំពត ។

ភូមិភាគ៤ : មានខេត្តស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង ។

ភូមិភាគ៥ : មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង ស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

## មាត្រា ២១.~

ក.គិ.ភ. មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋម មានសមាជិកពេញសិទ្ធចំនួន០៩ ( ប្រាំបួន ) រូប និងសមាជិកជំនួសចំនួន០៩ ( ប្រាំបួន ) រូប បោះឆ្នោតជ្រើសរើសក្នុងចំណោម ក.គិ.ខ. ក្នុងភូមិភាគ ។ ក.គិ.ខ. នីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិច០១( មួយ) រូបពេញសិទ្ធ និង ០១ ( មួយ) រូប ជាជំនួស ចំនួនអាសនៈដែលនៅសល់ត្រូវបែងចែកទៅ ខេត្ត ក្រុង ដោយផ្អែកទៅលើចំនួនគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលបានចុះឈ្មោះ ជាសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ភូមិភាគ។ សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោតជ្រើសរើស សំរាប់រយៈពេល០៦ ( ប្រាំមួយ) ឆ្នាំ ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួន នៅក្នុងរយៈពេល០២ (ពីរ) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ សមាជិកជំនួយត្រូវចូលជំនួសសមាជិកពេញសិទ្ធ នៅពេលដែលសមាជិកនេះអវត្តមាន ដោយមូលហេតុអ្វីក៏ដោយ ។

ការិយាល័យមានសមាសភាព: ប្រធាន០១ ( មួយ) រូប អនុប្រធាន០១ ( មួយ) រូប អគ្គលេខាធិការ០១ ( មួយ) រូប ហេរញ្ញិក ០១ ( មួយ) រូប និង សមាជិក ០៥ ( ប្រាំ) រូប។

## មាត្រា ២២.~

ប្រធាន ក.គិ.ខ. ប្រធាន ក.គិ.ភ. និងអគ្គលេខាធិការនៃក្រុមប្រឹក្សាទាំងនេះ មិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

## មាត្រា ២៣.~

អង្គប្រជុំ ក.គិ.ភ.ត្រូវបានចូលរួមក្នុងឋានៈជាអនុប្រធាននិងជាអ្នកពិគ្រោះយោបល់ដោយ ÷

- តំណាងឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ
- ទីប្រឹក្សាច្បាប់០១ ( មួយ) រូប ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម
- គិលានុបដ្ឋាក គិលានុបដ្ឋាយិកាការងារ០១ ( មួយ) រូបបើមាន ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
- នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ។

## មាត្រា ២៤.-

នៅក្នុងក្របខ័ណ្ឌគណៈគិលានុបដ្ឋាកភូមិភាគ ក.គិ.ភ. អនុវត្តការងាររបស់ខ្លួន តែទៅលើ សមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

ក.គិ.ភ. អាចទទួលពាក្យបណ្ដឹងជំទាស់ពី ក.គិ.ជ. ក.គិ.ខ. សមាគមគិលានុបដ្ឋាក រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធរខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការ ខេត្ត ក្រុង ឬសាមីគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈគិលានុបដ្ឋាក។

ក.គិ.ភ. ត្រូវពិនិត្យសំរេចនៅក្នុងរយៈពេលប្រាំមួយ(០៦)ខែយ៉ាងយូរ ក្រោយបានទទួលពាក្យបណ្ដឹង។ បើមិនដូច្នេះទេ ក.គិ.ជ. អាចបញ្ជូនពាក្យបណ្ដឹងនេះទៅ ក.គិ.ភ. ណាមួយផ្សេងទៀតដែលបានជ្រើសរើស។

## មាត្រា ២៥.-

គិលានុបដ្ឋាក គិលានុបដ្ឋាយិកាដែលកំពុងបំរើការនៅក្នុងសេវាសាធារណៈ ហើយបានសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈគិលានុបដ្ឋាកនឹងអាចអញ្ជើញមកបកស្រាយនៅចំពោះមុខ ក.គិ.ភ. បានចំពោះសកម្មភាពក្នុង មុខងារសាធារណៈរបស់ខ្លួនតែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ឬតាមរយៈព្រះរាជអាជ្ញាអមតុលាការតែប៉ុណ្ណោះ។

## មាត្រា ២៦.-

ការដាក់ទោសវិន័យត្រូវធ្វើឡើងនៅចំពោះមុខ គិលានុបដ្ឋាក គិលានុបដ្ឋាយិកាសាមី។ គិលានុបដ្ឋាក គិលានុបដ្ឋាយិកាសាមី អាចមានអ្នកការពារដែលជាគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ឬ ជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ បើគិលានុបដ្ឋាក គិលានុបដ្ឋាយិកាសាមីមិនព្រមចូលខ្លួនបំភ្លឺ ក.គិ.ភ. តាមការអញ្ជើញចំនួន០៣ (បី) លើកដោយគ្មានមូលហេតុច្បាស់លាស់ ក.គិ.ភ. នឹងអនុវត្តតាមចំណុចទី០៤ (បួន) ក្នុងមាត្រា២៨ (ម្ភៃប្រាំបី) នៃព្រះរាជក្រឹត្យនេះ។

## មាត្រា ២៧.-

ក.គិ.ភ. ត្រូវមានបញ្ជីកត់ត្រានូវរាល់ការប្រជុំដាក់វិន័យ។ ក.គិ.ភ. ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវដោយមានការបញ្ជាក់ និងចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវគេចោទសួរនោះផង ។

**មាត្រា ២៨.-**

ក.គិ.ភ. ដោយមានការចូលរួមពីផ្នែកវិន័យនៃ ក.គិ.ជ. អាចដាក់វិន័យដូចខាងក្រោម ÷

១- ការព្រមាន ។

២- សេចក្តីបន្ទោសដោយកត់ទុកក្នុងឯកសារផ្ទាល់ខ្លួន ។

៣- ហាមប្រកបវិជ្ជាជីវៈមួយរយៈពេលមិនលើសពី០៣(បី)ឆ្នាំ ឬជាអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬជាទូទៅនៃមុខងារ ជំនួយវេជ្ជសាស្ត្រដែលរដ្ឋទទួលស្គាល់

៤- ការលុបឈ្មោះចេញពីបញ្ជីគណៈគិលានុបដ្ឋាក

គិលានុបដ្ឋាក គិលានុបដ្ឋាយិកា ដែលត្រូវលុបឈ្មោះពីក្នុងបញ្ជីគណៈគិលានុបដ្ឋាក មិនអាចសុំចុះឈ្មោះនៅកន្លែងណាផ្សេងទៀតបានឡើយ ។

សេចក្តីដែលបានសំរេចចុងក្រោយដែលបានលើកឡើងត្រូវតែផ្សព្វផ្សាយទៅគ្រប់ ក.គិ.ខ. ព្រមទាំងទៅ ក.គិ.ជ. ។ ការសម្រេចរបស់ ក.គិ.ភ. ត្រូវតែមានហេតុផលច្បាស់លាស់ ។

**មាត្រា ២៩.-**

ក្រោយបានទទួលការលុបឈ្មោះចេញពីបញ្ជីអស់រយៈកាល០៣( បី )ឆ្នាំយ៉ាងតិចមក គិលានុបដ្ឋាក គិលានុបដ្ឋាយិកាដែលទទួលវិន័យ អាចទទួលការលើកលែងវិន័យ អំពីក្រុមប្រឹក្សាគណៈគិលានុបដ្ឋាក ដែលបានដាក់វិន័យដល់ខ្លួន ។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយគិលានុបដ្ឋាក គិលានុបដ្ឋាយិកាសាមី ។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះ ត្រូវបានបដិសេធក្រោយពីបានធ្វើការពិនិត្យ ពិចារណាស៊ីជំរៅមក ការស្នើសុំលើកលែងវិន័យសារជាថ្មី នឹងអាចធ្វើទៅបានតែក្នុងរយៈកាល០១( មួយ )ឆ្នាំ ទៅមុខទៀត ។

ចំពោះវិន័យអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬជាទូទៅនៃមុខងារវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់ មិនអាចស្នើសុំលើកលែងបានទេ ។

**មាត្រា ៣០.-**

ការអនុវត្តនីវិន័យរបស់គិលានុបដ្ឋាក គិលានុបដ្ឋាយិកា មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើ ជនល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

## ផ្នែកទី ៣

## ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ (ក.គិ.ជ.)

**មាត្រា ៣១.-**

ក.គិ.ជ. ត្រូវបានជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេល០៦ ( ប្រាំមួយ )ឆ្នាំ បែងចែកដូច

ខាងក្រោម

- តំណាងអោយខេត្ត ក្រុង នីមួយៗចំនួន០១( មួយ )រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោម សមាជិកគណៈគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ខេត្ត ក្រុងនោះ អ្នកជាប់ឆ្នោតត្រូវបាន បានទទួលស្គាល់ដោយប្រធានមន្ទីរសុខាភិបាល ខេត្ត ក្រុង
- តំណាងអោយរាជធានីភ្នំពេញចំនួន០២ ( ពីរ )រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោម សមាជិកគណៈគិលានុបដ្ឋាក គិលានុបដ្ឋាយិកា រាជធានីភ្នំពេញ។ អ្នកជាប់ឆ្នោតត្រូវបានទទួលស្គាល់ ដោយប្រធានមន្ទីរសុខាភិបាលរាធានីភ្នំពេញ
- តំណាងឱ្យអង្គភាពថ្នាក់កណ្តាលចំនួន០៥ (ប្រាំ )រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោម សមាជិកគណៈគិលានុបដ្ឋាក គិលានុបដ្ឋាយិកាថ្នាក់កណ្តាល និងបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- តំណាងឱ្យសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រចំនួន០១ ( មួយ )រូប ជ្រើសរើសដោយការបោះឆ្នោត ទទួលស្គាល់ដោយសកលវិទ្យាធិការ

## មាត្រា ៣២.

ក.គិ.ជ. ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួន១/៣ (មួយភាគបី) ក្នុងរយៈពេល០២( ពីរ ) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរសមាជិក១/៣ (មួយភាគបី) ម្តងៗ ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ត្រូវធ្វើការជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួនសំរាប់ ០២(ពីរ) ឆ្នាំម្តង ។

ការិយាល័យរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិកម្ពុជា រួមមានៈ ប្រធានក្រុមប្រឹក្សា ០១ (មួយ )រូប អនុប្រធានចំនួន០២ (ពីរ )រូប អគ្គលេខាធិការ០១ (មួយ )រូប អគ្គលេខាធិការរង០១ (មួយ )រូប ហេរញ្ញិក០១ (មួយ )រូប និង ហេរញ្ញិករង០១ (មួយ )រូប ។ ប្រធាន និងសមាជិក ក.គិ.ជ. ដែលចប់អាណត្តិ អាចឈរឈ្មោះឱ្យគេជ្រើសរើសសារជាថ្មីបាន។

## មាត្រា ៣៣.

ក.គិ.ជ. មានគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ចំនួន ០២ (ពីរ )រូប តំណាងឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ០១ (មួយ )រូប និង តំណាងឱ្យរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ០១ (មួយ )រូប ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ ។

## មាត្រា ៣៤.~

ក.គិ.ជ. មានផ្នែកវិន័យត្រូវមានសមាជិក០៧ (ប្រាំពីរ)រូប ដឹកនាំដោយប្រធាន ០១(មួយ)រូបជ្រើសតាំងក្នុងចំណោមសមាជិក០៧ (ប្រាំពីរ)រូបនេះ។ សមាជិកផ្នែកវិន័យ ត្រូវបានជ្រើសរើសតាមការបោះឆ្នោតក្នុងចំណោមសមាជិកការិយាល័យ នៃក្រុមប្រឹក្សា ក.គិ.ជ.។

ផ្នែកវិន័យមានភារកិច្ចដូចបានកំណត់ក្នុងមាត្រា ២៤ និង មាត្រា ២៨ នៃព្រះរាជក្រឹត្យនេះ។

## មាត្រា ៣៥.~

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួន១/៣ (មួយភាគបី) របស់ខ្លួន ក.គិ.ជ. ត្រូវធ្វើការជ្រើសតាំងផ្នែកវិន័យសារជាថ្មី ។

## មាត្រា ៣៦.~

ក.គិ.ជ . បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួនពេលបំពេញបេសកកម្មដូចមានចែងនៅក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ។

ក.គិ.ជ. ឃ្លាំមើលជាអាទិ៍ការគោរពអនុវត្តតាម របស់សមាជិកនៃគណៈគិលានុបដ្ឋាកទាំងអស់ចំពោះករណីយកិច្ចវិជ្ជាជីវៈ និង គោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុង ក្រមសីលធម៌គិលានុបដ្ឋាក។

ក.គិ.ជ. សហការជាមួយ ក.គិ.ខ. ធ្វើការសិក្សាដោះស្រាយនូវបញ្ហាស្មុគស្មាញទាំងឡាយ ដែលពាក់ព័ន្ធនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ គិលានុបដ្ឋាក គិលានុបដ្ឋាយិកា។

ក.គិ.ជ.បំពេញការងារនេះតាមរយៈផ្នែក និងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សានូវបណ្តាបញ្ហា ឬគំរោងការណ៍ទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

## មាត្រា ៣៧.~

ក.គិ.ជ. ត្រូវកំណត់អំពីចំនួនទឹកប្រាក់វិភាគទានឯកភាពមួយ ដែលសមាជិកម្នាក់ៗត្រូវបង់នៅពេលសុំចុះឈ្មោះ និងត្រូវបង់ប្រចាំឆ្នាំ ។

ក.គិ.ជ. ត្រូវកម្រិតផងដែរនូវចំនួនវិភាគទានដែល ក.គិ.ខ. ត្រូវបង់ជូនទៅ ក.គិ.ជ. ទៅ ក.គិ.ភ. និងត្រូវរក្សាទុកនៅក្នុង ក.គិ.ខ. ដើម្បីធានាចំណាយក្នុងការបំពេញការងារជាទូទៅ។ ការបង់វិភាគទានគឺជាកាតពកិច្ចរបស់សមាជិកម្នាក់ៗ។

ក.គិ.ជ. គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈគិលានុបដ្ឋាក និងអាចបង្កើត ឬឧបត្ថម្ភដល់

វណ្ណកម្មទាំងឡាយដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រ ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

ក.គិ.ជ. ត្រួតពិនិត្យការគ្រប់គ្រងរបស់ ក.គិ.ខ. និង ក.គិ.ភ. ។ ក.គិ.ខ ត្រូវរាយការណ៍ជូន ក.គិ.ជ. ជាមុន និងចម្លងជូនទៅ ក.គិ.ភ ចំពោះការបង្កើតអង្គការទាំងឡាយរបស់ខ្លួនព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

## មាត្រា ៣៨.–

ក.គិ.ជ. ត្រូវបង្កើតគណៈកម្មការ សំរាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង ។ សមាជិកនៃគណៈកម្មការនេះត្រូវជ្រើសរើសដោយ ក.គិ.ជ.ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យនៃក្រុមប្រឹក្សា។

ក្នុងដំណាច់ឆ្នាំនិមួយៗ គណៈកម្មការនេះ ត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូន ក.គិ.ជ.។

# ជំពូកទី៤
# អន្តរប្បញ្ញត្តិ

## មាត្រា ៣៩.–

ក្នុងអាណត្តិទី ១ នេះ សមាសភាព ក.គិ.ជ ត្រូវបានជ្រើសតាំង និងឯកភាពដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីដំណើរការអោយមានប្រសិទ្ធភាព ។

ក្នុងកំឡុងពេល០៦ (ប្រាំមួយ) ឆ្នាំដំបូង នៃអាណត្តិទី ១ សមាសភាពការិយាល័យរបស់ ក.គិ.ខ ក.គិ.ភ ត្រូវបានជ្រើសតាំងដោយសហភាតរៈរបស់ខ្លួន និងទទួលស្គាល់ដោយ ក.គិ.ជ.។

## មាត្រា ៤០.–

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវតែងតាំងក្រុមការងារមួយជាបណ្តោះអាសន្ន ដើម្បីរៀបចំដំណើរការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ៤១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

៣រល.០៧០៧.៣៩៧

លេខៈ ៣៧៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**